ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ..២៣៧/១៤១៣គ.ជ.អ.ប

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១៣

## គោរពជូន

## ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត

## កំពត កណ្តាល ព្រៃវែង ស្វាយរៀង និងខេត្តតាកែវ

**កម្មវត្ថុ** ÷ ការផ្តល់សោហ៊ុយធ្វើដំណើរបន្ថែមលើរបបប្រេងដល់មន្ត្រីគម្រោង និងបុគ្គលិកកិច្ចសន្យានៃគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច (PADEE) ។

**យោង** ÷ ស្មារតីឯកភាពនៃកិច្ចប្រជុំបច្ចេកទេសលើកទី៣ នៃគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច (PADEE) ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ផ្អែកតាមការពិភាក្សា និងឯកភាពគ្នា រវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គភាពគាំទ្រគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ត្រីគម្រោង និងបុគ្គលិកកិច្ចសន្យារបស់គម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច (PADEE) នឹងត្រូវផ្តល់នូវសោហ៊ុយធ្វើដំណើរដែលត្រូវអនុវត្តតាមអត្រាកំណត់របស់លេខាធិការដ្ឋានគ.ជ.អ.ប បន្ថែមទៅលើរបបប្រេង និងការថែទាំទោចក្រយានយន្តតាមករណីដូចខាងក្រោម ÷

-ការចុះបំពេញបេសកកម្មទៅស្រុក ឃុំគោលដៅរបស់មន្ត្រីគម្រោងថ្នាក់ខេត្ត និងបុគ្គលិកកិច្ចសន្យា

-ការទៅចូលរួមកិច្ចប្រជុំ បណ្តុះបណ្តាល និងទំនាក់ទំនងការងារក្នុងក្របខ័ណ្ឌគម្រោងនៅខេត្តគោលដៅរបស់មន្ត្រីគម្រោង និងបុគ្គលិកកិច្ចសន្យាថ្នាក់ស្រុក ឃុំ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប រៀបចំចាត់ចែង និងចូលរួមសហការតាមការគួរ ដើម្បីអនុវត្តគម្រោងនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

**ចម្លងជូន ÷**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"សូមជូនជ្រាប"
-អង្គភាពគាំទ្រគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-អង្គភាពអនុវត្តន៍គម្រោងនៃក្រសួងកិច្ចការនារី
-កាលប្បវត្តិ-ឯកសារ

**ហ. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**ង៉ាន់ ចំរើន**